# ច្បាប់

# ស្តីពី

# ស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ

**មាត្រា ១** គោលបំណង

ច្បាប់នេះមានគោលបំណងកំណត់ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដើម្បីពង្រឹងវិស័យសន្តិសុខសាធារណៈ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២** មធ្យោបាយបង្ហាញភស្តុតាង

១-សាក្សីទាំងអស់ដែលមានឈ្មោះក្នុងសំណុំរឿង រួមទាំងមន្ត្រីនគរបាលយុត្តិធម៌ផង ត្រូវតែបានអនុញ្ញាតនិយាយជូនតុលាការស្តាប់ ។ សាក្សីអាចត្រូវសួរដេញដោលពីសំណាក់ភាគីរដ្ឋប្បវេណី ឬទីប្រឹក្សាពីសំណាក់ជនជាប់ចោទ ឬទីប្រឹក្សាហើយនិងពីសំណាក់ព្រះរាជអាជ្ញា ។

២-នៅពេលជំនុំជម្រះ ភស្តុតាងទាំងអស់រួមទាំងកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ផង ត្រូវលើកយកមកជជែកវែកញែក ហើយភស្តុតាងនិងកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ទាំងនោះមិនអាចចាត់ទុកជាភស្តុតាងដែលមិនអាចប្រានចោលបានទេ ។

៣-បណ្តាពាក្យសារភាពរបស់ជនជាប់ចោទទាំងឡាយ ដែលមិនស៊ីសង្វាក់គ្នាទៅនឹងដើមកំណើតនៃភស្តុតាងទេទោះក្នុងករណីណាក៏ដោយ មិនអាចចាត់ទុកជាមូលដ្ឋានសម្រាប់ផ្តន្ទាទោសបានឡើយ ។ ពាក្យសារភាពដែលបានមកអំពីការ បង្ខិតបង្ខំតាមបែបណាមួយក៏ដោយ ត្រូវទុកជាមោឃៈ ។ ការសុំទុកជាមោឃៈនេះត្រូវស្នើទៅចៅក្រមដោយទីប្រឹក្សារបស់ជនជាប់ចោទនៅមុនពេលកាត់ក្តី។

៤-អ្នកការពារជនជាប់ចោទអាចយកសាក្សីខ្លួនមកបង្ហាញតុលាការ ហើយអាចជូនភស្តុតាងខ្លួនទៅតុលាការ ។

៥-សាក្សីទាំងអស់ ទាំងខាងដើមចោទ ទាំងខាងចុងចោទ អាចទទួលការបង្ខំឱ្យបង្ហាញខ្លួនចំពោះមុខតុលាការតាមរយៈដីកានាំខ្លួនរបស់តុលាការ ក្នុងករណីមិនព្រមប្រព្រឹត្តតាមការនាំខ្លួនរបស់តុលាការត្រូវពិន័យជាប្រាក់ពី ៥០.០០០ (ប្រាំម៉ឺន)រៀលទៅ ៥០០.០០០ (ហាសិបម៉ឺន)រៀល ។

**មាត្រា ៣** ឃាតកម្មគិតទុកជាមុន

១-ជនណាដែលសម្លាប់ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្រោយពីបានគិតទុកជាមុននូវបទឧក្រិដ្ឋរបស់ខ្លួនឬដោយបានរៀបចំការពួនស្ទាក់ ឬដែលបានសម្លាប់ ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀតក្នុងពេលដែលខ្លួនប្រព្រឹត្តចោរកម្ម ឬរំលោភសេពសន្ថវៈ ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតគិតទុកជាមុន ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី១៥ ឆ្នាំ ទៅ ២០ឆ្នាំ ឬអស់មួយជីវិត ។

២-ការគិតទុកជាមុន គឺគម្រោងធ្វើឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលណាម្នាក់ ។

ការពួនស្ទាក់គឺការឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលណាមួយដើម្បីប្រព្រឹត្តអំពើហិង្សាទៅលើបុគ្គលនោះ ។

**មាត្រា ៤** អំពើមនុស្សឃាតដោយចេតនា

ជនណាដែលសម្លាប់មនុស្សដោយចេតនាឬប៉ុនប៉ងសម្លាប់ជនណា ដោយចេតនាដោយគ្មានស្ថានទម្ងន់ណាដែលមានចែងក្នុងមាត្រា ៣ ដោយបានប្រើ ឬ មិនបានប្រើអាវុធក្តី ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១០ ទៅ ១៥ឆ្នាំ ។

ជនណាដែលសម្លាប់មនុស្សដោយចេតនាដោយឃោរឃៅក្នុងកាលៈទេសៈ និងក្នុងទីកន្លែងតែមួយ បណ្តាលឱ្យជនណាម្នាក់ឬច្រើននាក់ស្លាប់ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី១៥ឆ្នាំ,ទៅ២០ឆ្នាំ ឬអស់មួយជីវិត

**មាត្រា ៥** បទរំលោភសេពសន្ថវៈ

១-ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈលើជនណាម្នាក់ទៀត ទោះបីភេទដូចគ្នាឬមិនដូចគ្នាក៏ដោយ ត្រូវមានទោសពីបទរំលោភសេពសន្ថវៈ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ។

២-បទរំលោភសេពសន្ថវៈគឺគ្រប់អំពើបញ្ចូលអង្គជាតិ ឬមធ្យោបាយផ្សេងទៀតដោយឃោរឃៅ ដោយបង្ខំ ឬដោយមិនដឹងខ្លួនជាមុន ។

ប្រសិនបើការរំលោភសពសន្ថវៈបានប្រព្រឹត្តឡើងដោយការគំរាមកំហែងដោយអាវុធទៅលើស្ត្រីមានផ្ទៃពោះ លើជនមានជម្ងឺ ឬជនមានសតិវិបល្លាស ឬ ពិការរាងកាយ ឬលើអនីតិជនអាយុតិចជាង ១៤ឆ្នាំ ធ្វើឡើងដោយមានអ្នកប្រព្រឹត្តម្នាក់ ឬច្រើននាក់ ឬដោយអ្នកសមគំនិត ឬបើការសេពសន្ថវៈត្រូវប្រព្រឹត្តឡើងដោយជនដែលមានអំណាចលើអ្នករងគ្រោះ ទណ្ឌកម្មដែលត្រូវអនុវត្តគឺដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ។

**មាត្រា ៦** អំពើប្លន់

អំពើប្លន់ ជាការបន្លំនិងជាការជំរិតយកទ្រព្យសម្បត្តិអ្នកដទៃ តាមគ្រប់រូបភាពដោយផ្ទាល់ក្តី ដោយប្រយោលក្តី ក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

ជនណាដែលបានលួច ឬប៉ុនប៉ងលួចជនណាម្នាក់ទៀតដោយមានស្ថានទម្ងន់ទោសណាមួយដូចខាងក្រោមៈ

-ការលួចធ្វើដោយអំពើហិង្សាមានអាវុធ ឬអត់អាវុធ បណ្តាល ឬមិនបណ្តាលឱ្យមានរបួស

-ឬការលួចនោះ បានធ្វើឡើងដោយមានគ្នាច្រើន ឬដោយការកាប់គាស់ទម្លុះ ទម្លាយ បំផ្លិចបំផ្លាញ ត្រូវផ្តន្ទាទោសពីបទឧក្រិដ្ឋប្លន់ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ ទៅ ១០ឆ្នាំ ។

-ការលួចធ្វើដោយអំពើហិង្សាមានអាវុធក្តី ឬអត់អាវុធក្តី បណ្តាលឱ្យស្លាប់ម្ចាស់ទ្រព្យ ក្រុមគ្រួសារ ឬអ្នកការពារ អ្នកថែរក្សា ត្រូវមានទោសពីបទឧក្រិដ្ឋ ឃាតកម្មគិតទុកជាមុនហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី១៥ឆ្នាំ ទៅ២០ឆ្នាំ ឬអស់មួយជីវិត ។

**មាត្រា ៧** ការចាប់ជំរិតនិងការបង្ខាំងមនុស្សដោយខុសច្បាប់

១-ជនណាដែលគ្មានបញ្ជាពីអាជ្ញាធរតុលាការ បានចាប់ខ្លួន ឬឃុំខ្លួន ឬបង្ខាំងខ្លួន មនុស្សណាក៏ដោយត្រូវមានទោសៈ

-ដាក់ពន្ធនាគារ ៣ឆ្នាំ ទៅ ៥ឆ្នាំ បើការបង្ខាំងខ្លួននោះមានរយៈពេលតិចជាង១ ខែ

-ដាក់ពន្ធនាគារពី ៥ ឆ្នាំ ទៅ ១០ឆ្នាំ បើការបង្ខាំងខ្លួន ឬការឃុំខ្លួននោះមានរយៈពេលលើសពី១ខែ ។

២-ជនណាដែលគំរាមតាមគ្រប់រូបភាព តាមមធ្យោបាយណាក៏ដោយ ដើម្បីកំណត់ឱ្យប្រគល់ជាប្រាក់ ឬជាទ្រព្យសម្បត្តិ ក្នុងបំណងដែលខ្លួនចង់បាននោះត្រូវមានទោសពីបទឧក្រិដ្ឋជំរិតហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

៣-ជនណាដែលប្រព្រឹត្តដោយចេតនា ចាប់ខ្លួនជនណាម្នាក់ ឬច្រើននាក់ យកមកឃុំខ្លួន ឬបង្ខាំងខ្លួន ឬគំរាមធ្វើទារុណកម្មដោយគ្រប់រូបភាពបណ្តាលឱ្យជនណាម្នាក់ស្លាប់ក្តី ឬមិនស្លាប់ក្តី ហើយគំរាមឱ្យតតិយជន ឬជនរងគ្រោះប្រគល់ជាប្រាក់ ឬទ្រព្យសម្បត្តិ ឬអ្វីផ្សេងទៀត ដើម្បីជាថ្នូរទៅតាមបំណងរបស់ខ្លួនត្រូវមានទោសពីបទឧក្រិដ្ឋចាប់ជំរិតនិងបង្ខាំងមនុស្សខុសច្បាប់ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ឬអស់មួយជីវិត ។

**មាត្រា ៨** ការព្យួរទោស

ចំពោះបទឧក្រិដ្ឋនិងបទឧក្រិដ្ឋតម្រូវឱ្យធ្វើការ ចៅក្រមមិនត្រូវគិតពីស្ថានត្រាប្រណីទោស ឬបន្ធូរបន្ថយទោសក្រោមអប្បបរមា ឬព្យួរទោសបានឡើយ ។ ចំពោះបទមជ្ឈិមដែលមិនប៉ះពាល់ដល់របៀបរៀបរយសាធារណៈធ្ងន់ធ្ងរទេ អាចត្រូវព្យួរទោសទាំងមូល ឬមួយផ្នែកបាន ។ ក្នុងករណីនេះជនដែលបានប្រព្រឹត្តបទល្មើសមិនត្រូវទទួលរងទណ្ឌកម្មចប់ចុងចប់ដើមទេ ប្រសិនបើខ្លួនមិនបានប្រព្រឹត្តបទល្មើសមួយផ្សេងទៀតដែលមានចែងក្នុងបណ្ដាមាត្រាមុនៗក្នុងរយៈពេល ៥ឆ្នាំ ក្រោយពីការកាត់ទោសរបស់ខ្លួន ។

**មាត្រា ៩** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០** ច្បាប់នេះត្រូវ បានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមករា ឆ្នាំ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

**ស ខេង យូ ហុកគ្រី**

លេខ០៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាងី តាន**